# របាយការណ៍ប្រចាំឆ្នាំ
# ANNUAL REPORT 2023

Planting Seeds of Growth
We are ÆON



ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
**ÆON SPECIALIZED BANK (CAMBODIA) PLC.**

“ សាមញ្ញ រហ័ស និងងាយស្រួល ”

អ៊ីអន យើងតែងតែផ្ដល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលសាមញ្ញ រហ័សនិងងាយស្រួល

# មាតិកា


| | |
|---|---|
| រចនាសម្ព័ន្ធនៃអ៊ីអនគ្រុប | ០៤ |
| រចនាសម្ព័ន្ធនៃអេអេហ្វអេសគ្រុប | ០៥ |
| សង្ខេបព័ត៌មានហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៣ | ០៦ |
| សារពីគណៈគ្រប់គ្រង | ០៧ |
| ក្រុមប្រឹក្សាភិបាល | ០៨ |
| តារាងរចនាសម្ព័ន្ធចាត់តាំង | ១០ |
| ប្រវត្តិអាជីវកម្ម | ១១ |
| សមិទ្ធិផល ឆ្នាំ២០២៣ | ១២ |
| សង្ខេបព័ត៌មានអាជីវកម្មសំខាន់ៗឆ្នាំ២០២៣ | ១៣ |
| ទស្សនវិស័យអាជីវកម្ម ឆ្នាំ២០២៤ | ១៤ |
| ការត្រួតពិនិត្យផ្ទៃក្នុង | ១៥ |
| សកម្មភាពចូលរួម ទំនួលខុសត្រូវសង្គម | ១៦ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ១៧ |
| របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ | ១៨ |
| របាយការណ៍បម្រែបម្រួលមូលធន | ១៩ |
| របាយការណ៍លំហូរសាច់ប្រាក់ | ២០ |
| គោលការណ៍មូលដ្ឋានរបស់អ៊ីអន | ២២ |
| ចក្ខុវិស័យរបស់ក្រុមហ៊ុនរបស់អ៊ីអន | ២៣ |
| អំពីអ៊ីអនគ្រុប | ២៤ |

# បណ្ដាញនៃសម្ព័ន្ធក្រុមហ៊ុនអ៊ីអនហ្វាយនែនសលសឺវីស

> *ជួយលើកកម្ពស់ជីវភាពរស់នៅរបស់អតិថិជន និង ធ្វើឱ្យពួកគាត់ទទួលបាននូវកាលានុវត្តភាពនាពេលអនាគតជាអតិបរមាតាមរយៈការប្រើប្រាស់ឥណទានប្រកបដោយប្រសិទ្ធភាពខ្ពស់*



# រចនាសម្ព័ន្ធនៃអ៊ីអនគ្រុប

- Discount store Business
- Services & Specialty Store Business
- International Business
- Shopping Center Development Business
- **Financial Services Business**
- Health & Wellness Business
- Supermarket Business
- General Merchandise Store Business

AEON

# រចនាសម្ព័ន្ធនៃអេអេហ្វអេសគ្រុប

FINANCIAL SERVICES BUSINESS

**AFS Corporation Co., Ltd.**

- AEON SPECIALIZED BANK (CAMBODIA) PLC.
- AEON CREDIT SERVICE (PHILIPPINES) INC.
- AEON Housing Loan Service Co., Ltd.
- AEON Bank, Ltd.

**Consolidated subsidiaries overseas**

- AEON CREDIT SERVICE(M)BERHAD
- AEON THANA SINSAP(THAILAND) PUBLIC COMPANY LIMITED
- AEON CREDIT SERVICE(ASIA)CO.,LTD.
- KYOEI A&I Co., Ltd.
- Felica Pocket Marketing Inc.
- AEON Allianz Life Insurance Co., Ltd.
- ACS Leasing Co., Ltd.
- AEON S.S. Insurance Co., Ltd.
- ACS Credit Management Co., Ltd.
- AEON Insurance Service Co., Ltd.

# សង្ខេបព័ត៌មានហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២៣

## សារតារបស់យើង

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ("ក្រុមហ៊ុន") ត្រូវបានចុះបញ្ជីជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានម្រិត នៅប្រទេសកម្ពុជា ដែលបានចុះបញ្ជីដំបូងនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ក្រោមបញ្ជីការលេខ Co.២៣៨០E/២០១១ ចេញដោយក្រសួងពាណិជ្ជកម្ម និងបាន ចុះបញ្ជីសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម ក្រោមលេខចុះបញ្ជីការថ្មីលេខ ០០០០៦៣៨៤។ នៅថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០១១ ក្រុមហ៊ុនក៏បានទទួលអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា។ ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ យើងគឺជាអ្នកនាំមុខគេទីមួយក្នុងទីផ្សារកម្ពុជា ដែលផ្តល់ជូនអតិថិជននូវសេវាបង់រំលស់ដោយមិនទាមទារឲ្យមានទ្រព្យធានា ដូចជាផលិតផលប្រើប្រាស់ក្នុងផ្ទះ ម៉ូតូ ទូរស័ព្ទដៃ កម្ចីផ្ទាល់ខ្លួន និងសម្ភារៈកសិកម្ម។

នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ យើងទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារឯកទេស ពីធនាគារជាតិនៃកម្ពុជា។ ចាប់ពីពេលនោះមក យើងបានកម្លាយខ្លួនទៅជាធនាគារឯកទេស និងចាប់ផ្តើមពង្រីកអាជីវកម្មរបស់យើងដោយចេញប័ណ្ណឥណទាន អ៊ីអនរ៉ែលឡេត អ៊ីអនកាតម៉ូបាល (m-Visa) ជូនអតិថិជន។

ឆ្នាំ២០១៩ ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl. ដែលជាក្រុមហ៊ុនបានចុះឈ្មោះក្នុងទីផ្សារភាគហ៊ុនប្រទេសថៃ កាន់កាប់ភាគហ៊ុនចំនួន ៥០% ហើយភាគហ៊ុនចំនួន ៥០% ផ្សេងទៀត កាន់កាប់ដោយក្រុមហ៊ុន AFS Corporation Co., Ltd. ("AFSC") ជាក្រុមហ៊ុនឯកជន គ្រប់គ្រង១០០% ដោយ AEON Financial Service Co., Ltd. ("AFS") ដែលបានចុះបញ្ជីនៅក្នុងទីផ្សារភាគហ៊ុនTokyo Stock Exchange ។

## ទិន្នន័យហិរញ្ញវត្ថុសំខាន់

**ការលក់សរុប** (ឯកតា: '០០០ដុល្លារ)




**ប្រាក់ចំណូលសរុប** (ឯកតា: '០០០ដុល្លារ)




**គណនេយ្យទទួល** (ឯកតា: '០០០ដុល្លារ)




**ទ្រព្យសកម្មសរុប** (ឯកតា: '០០០ដុល្លារ)




**ចំនួនបុគ្គលិក**




**ចំនួនសាខា**




របាយការណ៍ហិរញ្ញវត្ថុសម្រាប់កាលបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ នេះត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"។ របាយការណ៍ហិរញ្ញវត្ថុសម្រាប់កាលបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានបង្ហាញ ជាលើកដំបូង ដោយអនុលោម តាមស្តង់ដាររបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "CIFRS"។

កំណត់សម្គាល់៖ ចាប់តាំងពីការិយបរិច្ឆេទដំបូង រហូតដល់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយអនុវត្តតាមស្តង់ដារគណនេយ្យនៃកម្ពុជា និងបទបញ្ញត្តិដែលពាក់ព័ន្ធនឹងគណនេយ្យផ្សេងៗ រួមទាំងបទបញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។



# សារពីគណៈគ្រប់គ្រង

**លោក Junji Noda**

អនុប្រធានក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយក

*យើងសូមណែនាំឲ្យស្គាល់ពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុនយើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។*

*អ្នកអានជាទីគោរព*

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ត្រូវបានបង្កើតឡើងនៅប្រទេសកម្ពុជាក្នុង ខែតុលា ឆ្នាំ ២០១១ ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលចាប់ផ្តើមជាមួយនឹងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដោយមិនមានទ្រព្យធានា។ យើងបានទទួលអាជ្ញាប័ណ្ណធនាគារឯកទេស ពីធនាគារជាតិនៃកម្ពុជា នៅ ខែតុលា ឆ្នាំ ២០១៥ ហើយបានចាប់ផ្តើមចេញប័ណ្ណឥណទាននៅឆ្នាំបន្ទាប់។ ក្នុងនាមជាក្រុមហ៊ុនមួយរបស់អ៊ីអនគ្រុប យើងសហការជាមួយ អ៊ីអន (ខេមបូឌា) និងអ៊ីអនម៉ល ដើម្បីពង្រីកអាជីវកម្មរបស់យើង។

ជំងឺរាតត្បាតសកលកូវីដ១៩ បាននាំឱ្យសេដ្ឋកិច្ចនៅទ្រឹង និងមានការរឹតត្បិតលើការបម្លាស់ទីរបស់ប្រជាជនក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ វាក៏បានពន្លឿនដល់ការផ្លាស់ប្តូរសេវាកម្មទៅជាឌីជីថលផងដែរ។ ប្រតិបត្តិការទូទាត់គឺត្រូវបានធ្វើឡើងតាមរយៈកម្មវិធីទូរស័ព្ទ មិនត្រឹមតែនៅផ្សារទំនើបប៉ុណ្ណោះទេ ថែមទាំងនៅតាមអាជីវកម្មខ្នាតតូចផងដែរ។

នៅឆ្នាំ ២០២៣ ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការដឹកជញ្ជូនម្ហូបអាហារ បានក្លាយជារឿងធម្មតា និងបន្តការរីកចម្រើន ចាប់តាំងពីមានជម្ងឺកូវីដ១៩។ ការធ្វើដំណើរក្នុងស្រុក និងក្រៅស្រុក និងការចាយវាយសរុបបានកើនឡើង ហើយដែលបង្ហាញពីសញ្ញានៃការត្រលប់មករកសភាពដើម បន្ទាប់ពីជម្ងឺរាតត្បាតសកលកូវីដ១៩។ ការទូទាត់ដោយគ្មានសាច់ប្រាក់បានកើនឡើងយ៉ាងគួរឱ្យកត់សម្គាល់ ហើយអតិថិជនក៏បានសម្របខ្លួនទៅតាមការផ្លាស់ប្តូរនេះ។

ដើម្បីសម្របទៅនឹងរបត់ទាំងនេះ យើងកំពុងអភិវឌ្ឍនូវសេវាកម្មទូទាត់ថ្មី ហើយគ្រោងនឹងផ្តល់ជូននូវកម្មវិធីទូរស័ព្ទដៃមួយដែលរួមបញ្ចូលគ្នានូវសេវាកម្មហិរញ្ញវត្ថុជាច្រើន។ យើងនឹងបន្តពង្រឹងមុខងារនៅក្នុងកម្មវិធីទូរស័ព្ទដូចជា "អ៊ីអន វ៉លឡែត" "អ៊ីអនកាតម៉ូបាល" និង "អ៊ីអនរហ័ស" ដើម្បីបង្កើនភាពងាយស្រួលដល់អតិថិជន។ លើសពីនេះ យើងបានពង្រីកបណ្តាញសាខារបស់យើង ដើម្បីបង្កើតបរិយាកាសងាយស្រួលសម្រាប់អតិថិជន។

ជាលទ្ធផល យើងទទួលបានពានរង្វាន់ឈានមុខពីវីសាលើអត្រាបើកការប្រើប្រាស់កាតច្រើនក្នុងឆ្នាំ២០២១ និងលើចំនួនប្រតិបត្តិការកាតឥណទាន ក្នុងឆ្នាំ២០២១ និងក្នុងឆ្នាំ២០២២ ហើយជាថ្មីម្តងទៀតទទួលបានពានលើការលក់ក្នុងបរិមាណច្រើនជាងគេពីបណ្ណឥណទានក្នុងឆ្នាំ២០២៣ ដែលនេះបង្ហាញថាក្រុមហ៊ុនរបស់យើងត្រូវបានគាំទ្រដោយអតិថិជនជាច្រើន។

នៅឆ្នាំ ២០២៤ ក្រុមហ៊ុនរបស់យើង នឹងបន្តវិនិយោគលើការប្រើប្រាស់ និងកែលម្អប្រព័ន្ធ ដើម្បីចាប់យកឱកាសក្នុងការផ្លាស់ប្តូរទៅជាឌីជីថល។ យើងផ្តោតលើការបង្កើតសេវាកម្មទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់ និងការកែលម្អលទ្ធភាពនៃការប្រើប្រាស់កម្មវិធីទូរសព្ទដៃ។

ជាចុងក្រោយ ក្នុងនាមក្រុមហ៊ុនយើងជាផ្នែកមួយនៃ អ៊ីអនគ្រុប យើងសហការជាមួយអ៊ីអន (ខេមបូឌា) និងអ៊ីអនម៉ល ដើម្បីផ្តល់ជូននូវផលិតផល និងសេវាកម្មដែលប្លែក និងផ្សេងពីស្ថាប័នហិរញ្ញវត្ថុដទៃទៀត ហើយយើងនឹងរួមចំណែកដល់បរិយាប័ន្នហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា តាមរយៈការធ្វើឲ្យប្រសើរឡើងនូវផលិតផល និងសេវាកម្មរបស់យើង។

យើងសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអតិថិជន ដៃគូអាជីវកម្ម និងសហការីរបស់យើងសម្រាប់ការគាំទ្រ និងការរួមចំណែកជាបន្តបន្ទាប់ចំពោះការអភិវឌ្ឍរបស់យើង។



**លោក Junji Noda**

អនុប្រធានក្រុមប្រឹក្សាភិបាល
និងជាអគ្គនាយក

# ក្រុមប្រឹក្សាភិបាល



## លោក Tsutomu Omodera

*មុខតំណែង ៖ ប្រធានក្រុមប្រឹក្សាភិបាល*
*ឆ្នាំកំណើត ៖ ១៩៦៤*
*កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រផ្នែកវិស្វកម្ម នៅសាកលវិទ្យាល័យ Kobe ប្រទេសជប៉ុន*

**២០២១ - បច្ចុប្បន្ន ៖**
ប្រធានក្រុមប្រឹក្សាភិបាលរបស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២០- បច្ចុប្បន្ន ៖**
អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយករបស់ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl.

**២០២០ - បច្ចុប្បន្ន ៖**
អភិបាលមិនប្រតិបត្តិ (កាន់តួនាទីជាប្រធាន) របស់ក្រុមហ៊ុន ACS Servicing (Thailand) Co., Ltd.

**២០១៨ - ២០២០ ៖**
អគ្គនាយករបស់ក្រុមហ៊ុន ACS Credit Management Co., Ltd. (ជប៉ុន)

**២០១៩ ៖**
អភិបាលមិនប្រតិបត្តិ របស់ក្រុមហ៊ុន AEON Credit Service Co., Ltd.

**២០១៥ - ២០១៩ ៖**
អភិបាល និងប្រធានប្រតិបត្តិ របស់ក្រុមហ៊ុន AEON Credit Service Co., Ltd.



## លោក Junji Noda

*មុខតំណែង ៖ អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក របស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី*
*ឆ្នាំកំណើត ៖ ១៩៧១*
*កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចនៅសាកលវិទ្យាល័យ Kansai ប្រទេសជប៉ុន*

**២០២២ - បច្ចុប្បន្ន ៖**
អនុប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក របស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២១ - ២០២២ ៖**
អភិបាលប្រតិបត្តិ នៃធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០១៥ - ២០២១ ៖**
អនុប្រធានប្រតិបត្តិរបស់ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl.

**២០១៣ - ២០១៥ ៖**
ប្រធានគ្រប់គ្រងជាន់ខ្ពស់ របស់ក្រុមហ៊ុន AEON Credit Service (ASIA) Co., Ltd

**២០០០ - ២០១៣ ៖**
ប្រធានគ្រប់គ្រងទូទៅ របស់ក្រុមហ៊ុន AEON Credit Service Co., Ltd.



## លោក Shuji Taniguchi

*មុខតំណែង ៖ អភិបាលប្រតិបត្តិ*
*ឆ្នាំកំណើត ៖ ១៩៧៥*
*កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យ Seikei ប្រទេស ជប៉ុន*

**២០២២ - បច្ចុប្បន្ន ៖**
អភិបាលប្រតិបត្តិរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២១ - ២០២២ ៖**
អ្នកគ្រប់គ្រងទូទៅ នាយកដ្ឋាន Group Corporate Sales Promotion របស់ក្រុមហ៊ុន AEON Credit Service Co., Ltd.

**២០១៨ - ២០២១ ៖**
ប្រធានសាខារបស់ក្រុមហ៊ុន AEON Credit Service Co., Ltd.

**២០០២ - ២០១៨ ៖**
បុគ្គលិកទទួលបន្ទុកផ្នែកសេវាហិរញ្ញវត្ថុ របស់ក្រុមហ៊ុន AEON Credit Services Co., Ltd.



## កញ្ញា Ryoko Yaoi

*មុខតំណែង ៖ អភិបាលប្រតិបត្តិ*
*ឆ្នាំកំណើត ៖ ១៩៧៤*
*កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រសិក្សាសង្គមទំនើបនៅសាកលវិទ្យាល័យ Otemae ប្រទេសជប៉ុន*

**២០២៣ - បច្ចុប្បន្ន ៖**
អភិបាលប្រតិបត្តិរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២១ - ២០២៣ ៖**
អ្នកគ្រប់គ្រងទូទៅ នាយកដ្ឋាន Group Operations Planning របស់ក្រុមហ៊ុន AEON Financial Service Co., Ltd.

**២០២០ - ២០២១ ៖**
អ្នកគ្រប់គ្រងទូទៅ នាយកដ្ឋានគ្រប់គ្រងផែនការប្រតិបត្តិការ របស់ក្រុមហ៊ុន AEON Financial Service Co., Ltd.

**២០១៨ - ២០២០ ៖**
អនុប្រធានប្រតិបត្តិជាន់ខ្ពស់ នាយកដ្ឋានទំនាក់ទំនង របស់ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl.

**២០១២ - ២០១៨ ៖**
អនុប្រធានប្រតិបត្តិជាន់ខ្ពស់ នាយកដ្ឋានគ្រប់គ្រងសេវាកម្មអតិថិជន របស់ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl.

**២០០៩ - ២០១២ ៖**
ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្មអតិថិជន របស់ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl.

**២០០៥ - ២០០៩ ៖**
ជំនួយការប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្មអតិថិជន របស់ក្រុមហ៊ុន AEON Thana Sinsap (Thailand) Pcl.

# អ្នកប្រឹក្សា



### ឯកឧត្តមបណ្ឌិត សុក ស៊ីផាន់ណា

*មុខតំណែង ៖ ទីប្រឹក្សា ( លាលែងពីតំណែងនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ )*
*ឆ្នាំកំណើត ៖ ១៩៦០*
*កម្រិតវប្បធម៌ ៖ បណ្ឌិតច្បាប់ (JD) មហាវិទ្យាល័យសាកលវិទ្យាល័យនីតីសាស្ត្រនៃ Widener University School of Law Delaware, (USA) បណ្ឌិតផ្នែកទស្សនវិជ្ជា (Ph.D) នៃ Bond University School of Law Queensland (Australia) បន្តប្បន្ន កំពុងបន្តការសិក្សា(Ph.D.)នៃសាកលវិទ្យាល័យ Paris 2 Pantheon Assas លើច្បាប់ប្រៀបធៀប*

**២០២៣ - បច្ចុប្បន្ន ៖**
ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស

**២០១៨ - សីហា ២០២៣ ៖**
ជាប្រធានកិត្តិយសនៃ Asian Vision Institute

**២០១៨ - សីហា ២០២៣ ៖**
ទីប្រឹក្សាជាន់ខ្ពស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចូលរួមជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**២០១៤ - សីហា ២០២៣៖**
ទីប្រឹក្សានៃ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០០៩ - សីហា ២០២៣៖**
ដៃគូគ្រប់គ្រង SokSiphana &associates

**១៩៩៨ - សីហា ២០២៣៖**
សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា



### លោក Yasuhiko Minakata

*មុខតំណែង ៖ អភិបាលមិនប្រតិបត្តិ*
*ឆ្នាំកំណើត ៖ ១៩៦១*
*កម្រិតវប្បធម៌ ៖ អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មនៅសាកលវិទ្យាល័យ ក្យូតុ ប្រទេសជប៉ុន*

**២០២៣ - បច្ចុប្បន្ន ៖**
អភិបាលមិនប្រតិបត្តិរបស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២២ - បច្ចុប្បន្ន ៖**
អភិបាលប្រតិបត្តិរបស់ក្រុមហ៊ុន AFS Corporation Co., Ltd.

**២០១៨ - ២០២២ ៖**
អភិបាលប្រតិបត្តិរបស់ក្រុមហ៊ុន AEON Insurance Service Co., Ltd.

**២០១៦ - ២០១៨ ៖**
អ្នកគ្រប់គ្រងទូទៅ នាយកដ្ឋានគ្រប់គ្រងក្រុមហ៊ុននៅក្រៅប្រទេសរបស់ក្រុមហ៊ុន AEON Financial Service Co., Ltd.

**២០១៦ - ២០១៨ ៖**
អភិបាលប្រតិបត្តិរបស់ក្រុមហ៊ុន AEON Insurance Brokers (HK) Limited

**២០១៤ - ២០១៦៖**
អ្នកគ្រប់គ្រងទូទៅនាយកដ្ឋាននីតិកម្ម និងប្រតិបត្តិតាមរបស់ក្រុមហ៊ុន AEON Financial Service Co., Ltd.

**២០១២ - ៖**
អ្នកគ្រប់គ្រងទូទៅរបស់នាយកដ្ឋានធនធានមនុស្ស និងទំនាក់ទំនងទូទៅរបស់ក្រុមហ៊ុន Japan Business Leasing Co., Ltd.

**២០១០ - ៖**
ប្រធានសាខានៃសាខា Shinjuku Shintoshin របស់ក្រុមហ៊ុន The Bank of Tokyo-Mitsubishi UFJ, Ltd.

**២០០៨ - ៖**
អនុប្រធានសាខានៃសាខា Shanghai របស់ក្រុមហ៊ុន The Bank of Tokyo-Mitsubishi Nichiren (China)



### លោកស្រី ខៀវ មាលី

*មុខតំណែង ៖ អភិបាលឯករាជ្យ*
*ឆ្នាំកំណើត ៖ ១៩៦៤*
*កម្រិតវប្បធម៌ ៖ បរិញ្ញាប័ត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យ Libre de Bruxelles (ULB) និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដោយសហការជាមួយសាកលវិទ្យាល័យ Montreal និងសាកលវិទ្យាល័យហ្សឺណែវ (LLM) និង LLB មកពីសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបរិញ្ញាបត្រច្បាប់នៅវិទ្យាស្ថានជាតិគ្រប់គ្រង និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច។*

**២០២៣ - បច្ចុប្បន្ន ៖**
អភិបាលឯករាជ្យរបស់ក្រុមហ៊ុន អេ អាយ អេ ខេមបូឌា

**២០២៣ - បច្ចុប្បន្ន ៖**
ទីប្រឹក្សាប្រធានរដ្ឋសភា

**២០២២ - បច្ចុប្បន្ន ៖**
អ្នកសម្របសម្រួលរបស់ CEDR

**២០១៩ - បច្ចុប្បន្ន ៖**
អនុប្រធាន និងសមាជិកស្ថាបនិកនៃ មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**២០១៧ - បច្ចុប្បន្ន ៖**
សមាជិកនៃ APAA and Council Member of APAA-Cambodian Group

**២០១៦ - បច្ចុប្បន្ន ៖**
សមាជិកនៃ ASEAN IPA- Country Head of Cambodian Group

**២០១៤ - បច្ចុប្បន្ន ៖**
អភិបាលឯករាជ្យរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០១២ - បច្ចុប្បន្ន ៖**
សហប្រធាននៃការិយាល័យនៃ SokSiphana & associates, សមាជិកនៃ ZICOLAW

**២០០៩ - បច្ចុប្បន្ន ៖**
ភ្នាក់ងារម៉ាកពាណិជ្ជកម្ម

**២០០៩ - បច្ចុប្បន្ន ៖**
សមាជិកស្ថាបនិកនៃ សមាគមកម្មសិទ្ធិបញ្ញាកម្ពុជា (IPAC)

**២០០៤ - បច្ចុប្បន្ន ៖**
សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា



### លោក សោភាន់ ចែត្រា

*មុខតំណែង ៖ អភិបាលឯករាជ្យ*
*ឆ្នាំកំណើត ៖ ១៩៧៧*
*កម្រិតវប្បធម៌ ៖ អនុបណ្ឌិតផ្នែកគ្រប់គ្រងហិរញ្ញវត្ថុពីសាកលវិទ្យាល័យតូហុគុ (Tohoku University) ប្រទេសជប៉ុន*

**២០២៣ - បច្ចុប្បន្ន ៖**
អភិបាលឯករាជ្យរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២៣ - បច្ចុប្បន្ន ៖**
អ្នកវិភាគហិរញ្ញវត្ថុរបស់ HGB Group Co. Ltd

**២០២២ - បច្ចុប្បន្ន ៖**
អភិបាលឯករាជ្យនៃ CPA Cambodia Program ក្រោមការគ្រប់គ្រងរបស់និយ័តករគណនេយ្យ និងសវនកម្ម (ACAR)

**២០២០ - បច្ចុប្បន្ន ៖**
ប្រធានក្រុមប្រឹក្សាភិបាលនៃក្លឹបគណនេយ្យកម្ពុជា (CAC)

**២០២០ - បច្ចុប្បន្ន ៖**
ទីប្រឹក្សាក្រុមហ៊ុន Acclime (Cambodia) Co. Ltd.

**២០១៩ - បច្ចុប្បន្ន ៖**
អភិបាលឯករាជ្យនៃក្រុមប្រឹក្សាភិបាល និងជាប្រធាននៃគណៈកម្មការគ្រប់គ្រងហានិភ័យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមហានគរ ម.ក

**២០១៥ - ២០២០ ៖**
ទីប្រឹក្សាផ្នែកហិរញ្ញវត្ថុ របស់ L.Y.P Group Co. Ltd រាជធានីភ្នំពេញ

**២០១៥ ៖**
ទីប្រឹក្សាហិរញ្ញវត្ថុ របស់ធនាគារពិភពលោកប្រចាំព្រះរាជាណាចក្រកម្ពុជា គំរោងទឹកស្អាត និងអនាម័យ

**២០១២ - ២០១៥ ៖**
នាយកប្រតិបត្តិ នៃក្រុមហ៊ុន Grow Greens Pte Ltd. និងនាយកប្រតិបត្តិ នៃក្រុមហ៊ុន SREDAL Co Ltd. រាជធានីភ្នំពេញ



### លោកស្រី ថៃ សុចាន់ណា

*មុខតំណែង ៖ អភិបាលឯករាជ្យ*
*ឆ្នាំកំណើត ៖ ១៩៨០*
*កម្រិតវប្បធម៌ ៖ បរិញ្ញាបត្រជំនាញគណនេយ្យ នៅវិទ្យាស្ថានជាតិគ្រប់គ្រង*

**២០២៣ - បច្ចុប្បន្ន ៖**
អភិបាលឯករាជ្យរបស់ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

**២០២១ - បច្ចុប្បន្ន៖**
នាយិកាប្រតិបត្តិផ្នែកហិរញ្ញវត្ថុក្រុមហ៊ុន FWD Life Insurance (Cambodia) PLC.

**២០១២ - ២០២១៖**
នាយិកាគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Manual Life (Cambodia) Plc.

**២០០៦ - ២០១២៖**
នាយិកាគ្រប់គ្រងផ្នែកហិរញ្ញវត្ថុនៅធនាគារ ANZ Royal Bank (Cambodia) Ltd.

**២០០៦ - ២០១០៖**
សវនករផ្ទៃក្នុង និងអ្នកត្រួតពិនិត្យលើការធានាគុណភាព នៅធនាគារ ANZ Royal Bank (Cambodia) Ltd.

**២០០៩ - ២០១០៖**
អ្នកប្រឹក្សាផ្នែកហិរញ្ញវត្ថុ នៅក្រុមកីឡាបាល់ទះជាតិ ( ជនពិការ )

**២០០១ - ២០០៦៖**
សវនករជាន់ខ្ពស់នៅ KPMG Cambodia Ltd.

# តារាងរចនាសម្ព័ន្ធចាត់តាំង



# ប្រវត្តិអាជីវកម្ម

## ២០១៥

តុលា ទទួលបានអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារឯកទេស

វិច្ឆិកា ដាក់ឱ្យដំណើរការពាក្យស្នើសុំតាមប្រព័ន្ធ Online




## ២០១៦

កុម្ភៈ កម្លាយខ្លួនទៅជាធនាគារឯកទេស

មេសា កែលំអសាខាអ៊ីអនម៉ល ភ្នំពេញ

មេសា ចាប់ផ្តើមផ្តល់កាតអ៊ីអន ពណ៌មាស

កក្កដា ចាប់ផ្តើមផ្តល់កាតអ៊ីអន ពណ៌ស្វាយ




## ២០១៧

មករា បើកសម្ពោធសាខាពោធិ៍ចិនតុង

កក្កដា ទីស្នាក់ការកណ្តាល និងផ្លាស់ប្តូរអាសយដ្ឋានសាខាខេត្តបាត់ដំបង

សីហា កែលំអការិយាល័យកណ្តាល

តុលា កែលំអ និងផ្លាស់ប្តូរអាសយដ្ឋានសាខាខេត្តសៀមរាប

ធ្នូ ទទួលបានពានរង្វាន់ពី VISA



## ២០១៨

មេសា ដាក់អោយដំណើរការ អ៊ីអនវ៉លឡេត

មេសា ចាប់ផ្តើមបង់រំលស់រថយន្ត

មិថុនា បើកសម្ពោធសាខា អ៊ីអន សែនសុខ

សីហា បើកសម្ពោធសាខាខេត្តតាកែវ

សីហា បើកសម្ពោធសាខាខេត្តបន្ទាយមានជ័យ

ធ្នូ ដាក់អោយដំណើរការ អ៊ីអនកាតម៉ូបាល (Scan to Pay)



## ២០១៩

មេសា ផ្លាស់ប្តូរអាសយដ្ឋានការិយាល័យកណ្តាល

មិថុនា កែលម្អ សាខាខេត្តបន្ទាយមានជ័យ

កក្កដា ប្តូរទីតាំង និងប្តូរឈ្មោះពី សាខាសុវណ្ណា ទៅជាសាខាស្ទឹងមានជ័យ

សីហា កែលម្អ និងផ្លាស់ប្តូរអាសយដ្ឋានសាខាខេត្តតាកែវ

វិច្ឆិកា បើកសម្ពោធសាខាច្បារអំពៅ



## ២០២០

ឧសភា ការកែលម្អ សាខាពោធិ៍ចិនតុង

សីហា ការកែលម្អ សាខាបាត់ដំបង

ធ្នូ ទទួលបានពានរង្វាន់ពី VISA




## ២០២១

ឧសភា ការកែលម្អ កន្លែងសម្រាក អ៊ីអនឡេញ សែនសុខ

សីហា ដាក់អោយដំណើរការ អូឡាំពិចកាតហ្វេស




## ២០២២

មករា ដាក់អោយដំណើរការ អ៊ីអនរហ័ស

ឧសភា ការកែលំអកន្លែងសម្រាក អ៊ីអនឡេញ ភ្នំពេញ

តុលា ដាក់អោយដំណើរការ FIFA កាតហ្វេស

ធ្នូ ទទួលបានពានរង្វាន់ពី VISA ២០២១ & ២០២២




## ២០២៣

កុម្ភៈ បើកសម្ពោធសាខាអ៊ីអនម៉លមានជ័យ

កុម្ភៈ បើកសម្ពោធសាខាខេត្តកំពង់ស្ពឺ

កញ្ញា បើកសម្ពោធសាខាខេត្តកំពង់ធំ

វិច្ឆិកា បើកសម្ពោធសាខាខេត្តកំពត

ធ្នូ ទទួលបានពានរង្វាន់ពី VISA





## សមិទ្ធិផល ឧបសគ្គ និងការគំរាមកំហែងពីមុន

### ១. ការពង្រីកបន្ថែមនូវដៃគូសហការ / ដៃគូអាជីវកម្ម




១.១. យើងបានបង្កើនទំនាក់ទំនងជាមួយហាងដែលជាដៃគូសហការថ្មីចំនួន ៥០២ បន្ថែមទៀតនៅក្នុងឆ្នាំ ២០២៣ ប៉ុន្តែយើងបានបិទការសហការជាមួយដៃគូចំនួន៣៥៣ ដែលធ្វើឱ្យដៃគូសរុបកើនដល់ ៣.៨៥៨។ កំណើនដៃគូសហការ កើនឡើងដោយសារតែសកម្មភាពដ៏សកម្មដែលធ្វើឡើងនៅក្នុងតំបន់ប្រតិបត្តិការ និងការបង្កើនទំនាក់ទំនងជាមួយនឹងដៃគូសហការដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

១.២ យើងបានបង្កើត និងបន្តអាជីវកម្មជាមួយម៉ាកយីហោដែលជាដៃគូសហការ ចំនួន ២២៣ម៉ាក ដែលក្នុងនោះមានចំនួនហាង ២៦៣កន្លែង ក្នុងឆ្នាំ២០២៣។ សរុបជាលទ្ធផលរួមទាំងអស់ យើងទទួលបានយីហោដៃគូសហការរហូតដល់ទៅ ៨៣២ម៉ាក និងចំនួនហាង ១.១០៧ កន្លែង។

១.៣. បង្កើត និងបន្តទំនាក់ទំនងអាជីវកម្មជាមួយនឹងហាងដែលប្រើប្រាស់អ៊ីអនកាតម៉ូបាលមានចំនួន ២៨៣ ម៉ាក និងហាងចំនួន ៣៣១ កន្លែង ក្នុងឆ្នាំ ២០២៣។ ដែលសរុបទាំងអស់មានចំនួនម៉ាកយីហោរហូតដល់ទៅ ១.២១៨ ម៉ាក និង ហាងចំនួន ១.៤៤៣ កន្លែង។

១.៤. បង្កើនទំនាក់ទំនងអាជីវកម្មជាមួយហាងដែលប្រើប្រាស់ អ៊ីអនវ៉ាលឡេត ដែលមានចំនួនសរុបទាំងអស់ ៥៣៦ ហាង គិតត្រឹមបំណាច់ឆ្នាំ ២០២៣ ទាំងនៅផ្សារទំនើបអ៊ីអនម៉លភ្នំពេញ និងផ្សារអ៊ីអនម៉លសែនសុខស៊ីធី និងហាងខាងក្រៅផ្សេងទៀត។

### ២. ការពង្រឹងការបំពេញសេវាកម្មជូនអតិថិជន

២.១. ដើម្បីបម្រើសេវាកម្មជូនអតិថិជនឱ្យកាន់តែប្រសើរឡើង យើងមិនត្រឹមតែបន្តពង្រឹងប្រព័ន្ធ/លទ្ធភាពរបស់មជ្ឈមណ្ឌលហៅទូរសព្ទរបស់យើងឱ្យកាន់តែរឹងមាំប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ការបណ្តុះបណ្តាលជាប្រចាំដល់បុគ្គលិក/ភ្នាក់ងាររបស់មជ្ឈមណ្ឌលទូរសព្ទរបស់យើង ដើម្បីឆ្លើយតបការហៅទូរស័ព្ទរបស់អតិថិជនប្រកបដោយប្រសិទ្ធភាពផងដែរ។

២.២. ក្រៅពីការពង្រឹងបន្ថែមប្រព័ន្ធ និងបុគ្គលិករបស់យើង យើងបានបង្កើនបណ្តាញបន្ថែមដើម្បីអាចឲ្យអតិថិជនចូលប្រើប្រាស់ ក្នុងការបង្ហាញពីមតិកែលម្អ ឬការផ្តល់យោបល់របស់ពួកគេតាមរយៈ ទូរស័ព្ទបន្ទាន់ hotline, ហ្វេសប៊ុក គេហទំព័រ/អ៊ីម៉ែល កម្មវិធីទូរស័ព្ទដៃ មតិកែលម្អតាមរយៈប្រអប់ផ្តល់យោបល់តាមបណ្តាសាខា។ ព័ត៌មានបន្ថែមអំពីបណ្តាញទាំងនេះ គឺអាចរកបានពេញលេញ និងមានបង្ហាញនៅលើគេហទំព័ររបស់យើងផងដែរ។

### ៣. ឥណទានបុគ្គល & ការបង់រំលស់ បន្តកើនឡើងនៅឆ្នាំ ២០២៣

ដោយផ្តោតលើការផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធអនឡាន និងជំនាន់ថ្មីនាំមុខពីបណ្តាញឌីជីថល ការលក់សរុបសម្រេចបាន ១០១.៥លានដុល្លារអាមេរិក ស្មើនឹង ១៥៦ភាគរយ បើធៀបនឹងឆ្នាំមុន។ យើងបន្តរក្សាទំនាក់ទំនង និងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូសំខាន់ៗ អ្នកចែកចាយបន្ត និងដៃគូលក់ទាំងឡាយ។



# សង្ខេបព័ត៌មានអាជីវកម្មសំខាន់ៗ ឆ្នាំ២០២៣

## សកម្មភាពឆ្នាំ ២០២៣

យើងបានផ្តោតលើការពង្រីកកំពូលបណ្តាញដែលបានធ្លាក់ចុះក្នុងអំឡុងពេលជម្ងឺរាតត្បាតសកលកូវីដ ១៩ និងការផ្តល់សេវាកាន់តែប្រសើរឡើងក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរបរិយាកាស និងតម្រូវការរបស់អតិថិជន។ សម្រាប់កាតឥណទាន យើងបានធ្វើយុទ្ធនាការទៅលើ E-Commerce និងការដឹកជញ្ជូនអាហារ ដែលបានក្លាយជារឿងធម្មតាចាប់តាំងពីជម្ងឺរាតត្បាតសកលមក។ យើងក៏បានផ្តល់ជូនអតិថិជនកាតឥណទានរបស់យើងនូវអត្ថប្រយោជន៍ និងសិទ្ធិពិសេសប្រើប្រាស់កាត ដែលពួកគេអាចទទួលបាននៅហាងដៃគូសហការរបស់យើង។

ដោយសារតម្រូវការប្រាក់កម្ចីមានការកើនឡើង យើងបានធ្វើឱ្យប្រសើរឡើងនូវទីផ្សារផលិតផល ដូចជាការបង្កើនកម្រិតឥណទាន និងអនុវត្តការផ្សព្វផ្សាយការប្រាក់ទាប។ ដើម្បីពង្រីកបណ្តាញសាខា និងនាំយកផលិតផល និងសេវាកម្មរបស់យើងទៅកាន់អតិថិជនកាន់តែច្រើន យើងបានបន្តបើកសាខាថ្មីចំនួន ៤ ទៀត។ ដោយឡែក បញ្ហាមួយចំនួននៅតែមិនទាន់អាចដោះស្រាយបាន។ យើងមិនអាចទទួលបានលទ្ធផលនៃការលក់គ្រប់តាមផែនការទេ ដោយសារយើងមិនទាន់ដឹងគ្រប់គ្រាន់អំពីការផ្លាស់ប្តូរនៅក្នុងលក្ខខណ្ឌសេដ្ឋកិច្ច និងការចាយវាយរបស់អតិថិជនរបស់យើង។ លើសពីនេះ យើងបានពន្យារការដាក់ឱ្យប្រើប្រាស់ VISA Prepaid ។ យើងនឹងត្រូវចាត់វិធានការស្តារឡើងវិញនៅឆ្នាំក្រោយនេះ។

## ផែនការ និងការអនុវត្តអាទិភាពសម្រាប់ឆ្នាំ ២០២៤

ដោយផ្អែកលើការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចចាប់តាំងពីជម្ងឺរាតត្បាតសកល និងការកើនឡើងជាបន្តបន្ទាប់នៃទីផ្សារហិរញ្ញវត្ថុ យើងនឹងបន្តផ្តោតលើការពង្រីកកំពូលជាពិសេសសម្រាប់ផលិតផលបង់រំលស់។ ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន និងដៃគូអាជីវកម្មបង់រំលស់របស់យើង យើងនឹងបង្កើនល្បឿននៃការសិក្សាសំណើឥណទាន និងដំណើរការវិនិច្ឆ័យរបស់យើង ដោយកាត់បន្ថយទម្រង់ពាក្យសុំ និងអនុវត្តគម្រោងការអនុម័តថ្មី។ ទាក់ទងនឹងគម្រោងធ្វើបច្ចុប្បន្នភាពអាជីវកម្មលុយអេឡិចត្រូនិកដែលត្រូវបានផ្អាកក្នុងអំឡុងពេលជម្ងឺរាតត្បាតសកល យើងនឹងបើកដំណើរការ VISA Prepaid នៅឆ្នាំនេះ ដែលនឹងផ្តល់ជូនអតិថិជនរបស់យើងនូវអត្ថប្រយោជន៍ និងសិទ្ធិអាទិភាពនៅហាងដៃគូសហការរបស់យើង។ ជាចុងក្រោយ យើងបានចាប់ផ្តើម “សេវាកម្មធនាគារ ៧ ថ្ងៃ” នៅគ្រប់សាខាទាំងអស់ បន្ថែមពីលើសាខាចំនួន ៣ នៅក្នុងផ្សារទំនើប អ៊ីអនម៉ល។ ដើម្បីកាន់តែខិតឲ្យជិតអតិថិជន។ យើងនឹងព្យាយាមកែលម្អសេវាកម្មរបស់យើងឱ្យកាន់តែងាយស្រួល និងនាំយកសេវាកម្មរបស់យើងទៅកាន់អតិថិជនកាន់តែច្រើន។



# ទស្សនវិស័យអាជីវកម្ម ឆ្នាំ២០២៤

## ប័ណ្ណឥណទាន




ក្រុមហ៊ុនយើង នៅតែឈរក្នុងលំដាប់លេខ១ និងបានកាន់កាប់រហូតដល់ ២៩%នៃចំនួនប័ណ្ណឥណទានសរុបដែលបានចេញនៅក្នុងប្រទេសកម្ពុជា។ យើងមាន កាតដែលមានសុពលភាពសរុបចំនួន ៤៣.៩៤២ កាត គិតត្រឹម ខែធ្នូ ឆ្នាំ២០២៣ និងឈរក្នុងលំដាប់លេខ១ ចំពោះការទូទាត់តាមប័ណ្ណឥណទាន និងបានកាន់កាប់រហូតដល់ ១៣% នៅក្នុងទីផ្សារ (យោងតាមរបាយការណ៍របស់VISA ក្នុងត្រីមាសទី៤ ឆ្នាំ ២០២៣)។

សូមអរគុណដល់អតិថិជនដែលជាម្ចាស់អ៊ីអនកាត ដៃគូសហការ និងការខិតខំប្រឹងប្រែងរបស់បុគ្គលិកទាំងអស់របស់ក្រុមហ៊ុន សម្រាប់ការខិតខំប្រឹងប្រែង និងធ្វើអោយសមិទ្ធិផលមួយនេះសម្រេចទៅបានដោយជោគជ័យ។

ក្រុមហ៊ុនយើងនៅតែបន្ត និងធ្វើការពង្រឹងបន្ថែមនូវកម្មវិធីសន្សំពិន្ទុ “Happy Plus Point” ដែលផ្តល់ជូនអតិថិជននូវជម្រើសជាច្រើនសម្រាប់ការប្តូរពិន្ទុ ដូចជា៖ សន្លឹកប័ណ្ណទូទាត់ជាទឹកប្រាក់ វត្ថុអនុស្សាវរីយ៍ និងការបញ្ចូលទឹកប្រាក់ទៅក្នុងអ៊ីអនកាតរបស់អតិថិជនផ្ទាល់ ដើម្បីផ្តល់ជាអត្ថប្រយោជន៍ពីការប្រើប្រាស់របស់ពួកគេ។ យើងបានធ្វើការផ្សព្វផ្សាយជាច្រើនដើម្បីរក្សានៅការប្រើប្រាស់ពីអតិថិជន ជាមួយដៃគូសហការ ដូចជា ការចាក់សាំងបានប្រាក់ត្រឡប់មកវិញ ញ៉ាំមួយថែមមួយ ធ្វើការកម្មង់អាហារ ធ្វើដំណើរកំសាន្ត ការស្នាក់នៅ បញ្ជាទិញទំនិញពីក្រៅប្រទេស និងប្រម៉ូសិនផ្សេងៗជាច្រើនទៀត។

អតិថិជនអ៊ីអនកាតរបស់ក្រុមហ៊ុនយើង នឹងទទួលបាននូវការផ្តល់នូវអត្ថប្រយោជន៍បន្ថែម ដោយទទួលបាននូវការបញ្ចុះតម្លៃរហូតដល់ ៥០% ជាមួយដៃគូសហការជាង ១.១០៧ ហាង។ យើងបានបន្តពង្រីកបន្ថែមដៃគូសហការ និងជួយគាំទ្រដល់អាជីវកម្មខ្នាតតូច ដើម្បីរក្សានៅការទូទាត់ដោយមិនប្រើប្រាស់ក្រដាសប្រាក់បន្ថែមចំនួន១.២១៨ ម៉ាក និង ១.៤៤៣ ហាង ត្រឹមខែធ្នូ ឆ្នាំ ២០២៣ (ដៃគូសហការដែលឈរនៅចំណាត់ថ្នាក់កំពូលគឺ ផ្នែកអាហារ និងភេសជ្ជៈមាន ៦១% សម្លៀកបំពាក់ និង គ្រឿងតុបតែងខ្លួនមាន ១៩% ការថែទាំសុខភាពមាន ១២%% និង៨% សម្រាប់ប្រភេទផ្សេងៗទៀត)។ ដៃគូសហការភាគច្រើនគឺជាអាជីវកម្មខ្នាតតូច ដូច្នេះការទូទាត់មានទំហំទឹកប្រាក់តិចតួច ដែលធ្វើឲ្យយើងអាចបង្កើនការទូទាត់តាមទូរស័ព្ទដៃ និងកាត់បន្ថយការប្រើប្រាស់ក្រដាសប្រាក់នៅក្នុងទីផ្សារ។

ក្រុមហ៊ុនយើង នឹងបន្តធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាព/មុខងារ ផលិតផលរបស់យើង ដើម្បីផ្តល់ជូននូវសេវាកម្មល្អបំផុត ជូនចំពោះអតិថិជន ដែលជាម្ចាស់ អ៊ីអនកាត ដោយធ្វើឲ្យប្រសើរឡើង និងកាន់តែមានភាពសាមញ្ញ។

## ឥណទានបុគ្គលជាប្រាក់រៀល

ដើម្បីគាំទ្រគំនិតផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជាក្នុងការលើកកម្ពស់ប្រាក់រៀល យើងបន្តផ្តោតទៅលើការធ្វើអោយប្រសើរឡើងនូវកម្ចីប្រាក់រៀលឲ្យស្របតាមលក្ខខណ្ឌរបស់ធនាគារជាតិនៃកម្ពុជា។ ក្នុងឆ្នាំ ២០២៣ កម្ចីជាប្រាក់រៀលមានចំនួន១៣,៨%នៃផលប័ត្រសរុប ខណៈដែលឥណទានបុគ្គល នៅតែជាផលិតផលសំខាន់របស់យើងក្នុងការជំរុញកម្ចីប្រាក់រៀល។ នៅឆ្នាំ ២០២៣ យើងនៅតែបន្តលើកកម្ពស់ និងគាំទ្រកម្ចីប្រាក់រៀលរបស់យើង តាមរយៈការបើកដំណើរការកម្ចីប្រាក់រៀលនៅក្នុងផលិតផលបង់រំលស់ម៉ូតូដើម្បីបំពេញតាមតម្រូវការបទប្បញ្ញត្តិ ក៏ដូចជាការផ្សព្វផ្សាយប្រាក់រៀលនៅលើទីផ្សារ។

## ការសម្រេចគោលដៅឆ្នាំសារពើពន្ធ ២០២៤

ផលិតផលកម្ចីរថយន្ត ផលិតផលកម្ចីម៉ូតូ និងផលិតផលកម្ចីទូទៅ គឺជាផលិតផលសំខាន់ដែលត្រូវផ្តោតលើសម្រាប់ឆ្នាំសារពើពន្ធ ២០២៤ ជាមួយនឹងយុទ្ធសាស្រ្តដ៏មានប្រសិទ្ធភាពដែលបានកំណត់ និងសកម្មភាពអាជីវកម្មបន្ថែមដោយសេចក្តីសង្ខេបខាងក្រោម

### ១. ប្រតិបត្តិការធនាគារ

ពង្រីកប្រតិបត្តិការធនាគារដល់ចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក (សេវាកម្ម៧ថ្ងៃក្នុងមួយសប្តាហ៍) ដើម្បីជម្រុញភាពងាយស្រួលដល់អតិថិជន និងផ្សព្វផ្សាយឲ្យអតិថិជនស្គាល់ពីធនាគាររបស់យើង។

### ២. ប៉េងកាសួរេន

ការចាប់ផ្តើមអាជីវកម្ម ប៉េងកាសួរេន ក្រោមម៉ូឌែលណែនាំអតិថិជន ជាដៃគូ ជាមួយក្រុម ហ៊ុន ធានារ៉ាប់រង ដើម្បីពង្រីកឱកាសអាជីវកម្ម និងផ្តល់ភាពងាយស្រួល សុវត្ថិភាពដល់អតិថិជន។

### ៣. បម្លាស់ផ្លាស់ប្តូរឌីជីថល

ដើម្បីបង្កើនប្រតិបត្តិការ ឬដំណើរការក្នុងការផ្លាស់ប្តូរឌីជីថលក្នុងគោលបំណងរក្សានិន្នាការរបស់ឌីជីថល និងបង្កើនភាពប្រកួតប្រជែងនៅក្នុងទីផ្សារ។

# ការត្រួតពិនិត្យផ្ទៃក្នុង

## ការប្រតិបត្តិតាមរបស់ធនាគារ



ការត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព បង្ហាញពីភាពរឹងមាំ និងសុវត្ថិភាពរបស់ដំណើរការធនាគារ។ ការរៀបចំដ៏សមស្រប និងការពង្រឹងប្រព័ន្ធប្រតិបត្តិការ និងការត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយសង្គត្តិភាព ជួយឲ្យក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន រក្សាបាននូវធនធាន ចេញនូវរបាយការណ៍ហិរញ្ញវត្ថុដ៏គួរឲ្យទុកចិត្ត និងប្រតិបត្តិតាមនូវរាល់ច្បាប់ និងបទបញ្ញត្តិផ្សេងៗ។ ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង ក៏ជួយកាត់បន្ថយនូវឱកាសនៃការកើតឡើងនូវបញ្ហាសំខាន់ៗ និងភាពមិនប្រក្រតី មួយចំនួន ព្រមទាំងជួយក្នុងការទប់ស្កាត់នូវបញ្ហាទាំងនោះទាន់ពេលវេលា នៅពេលដែលវាបានកើតឡើង។ ក្នុងនោះដែរ មុខងារប្រតិបត្តិតាម ពិតជាចូលរួមចំណែក និងដើរតួនាទីយ៉ាងសំខាន់ នៅក្នុងសកម្មភាពនៃការត្រួតពិនិត្យផ្ទៃក្នុងជាលក្ខណៈអចិន្ត្រៃយ៍របស់ក្រុមហ៊ុន។ ក្នុងនាមជាអ្នកការពារនៅស្រទាប់ទី២ ដោយផ្តាច់ចេញពីមុខងារការត្រួតពិនិត្យផ្ទៃក្នុងដទៃទៀតរបស់ក្រុមហ៊ុន មុខងារប្រតិបត្តិតាម គឺជាមុខងារដែលឯករាជ្យ ដែលមិនពាក់ព័ន្ធជាមួយនឹងប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន ដើម្បីបញ្ចៀសពីទំនាស់នៃផលប្រយោជន៍។ តួនាទីដ៏សំខាន់របស់មុខងារប្រតិបត្តិតាម គឺដើម្បីធានាឲ្យបានថា ប្រតិបត្តិការ រចនាសម្ព័ន្ធ និងនីតិវិធីត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុន អនុលោមតាមច្បាប់ និងបទបញ្ញា ពាក់ព័ន្ធ ក្រមសីលធម៌ ទម្លាប់នៃការអនុវត្តប្រតិបត្តិការ និងយុទ្ធសាស្ត្រអាជីវកម្ម ដែលត្រូវបានកំណត់ដោយគណៈប្រតិបត្តិ។ នៅក្នុងឆ្នាំ ២០២៣ ផ្នែកប្រតិបត្តិតាម បានធ្វើបច្ចុប្បន្នភាពទៅលើ គោលនយោបាយ បទបញ្ញត្តិ និងនីតិវិធី ដែលទាក់ទងទៅនឹងក្របខណ្ឌប្រតិបត្តិតាម និងទៅលើគោលនយោបាយ បទបញ្ញត្តិ និងនីតិវិធីដទៃទៀត ដើម្បីឲ្យមានភាពសមស្របទៅនឹងការរីកចម្រើននៃផលិតផល សេវាកម្ម និន្នាកាទីផ្សារ និងជាពិសេស ឲ្យស្របទៅនឹងច្បាប់ និងបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀត ឯកសារនិងសម្ភារៈដែលប្រើប្រាស់ក្នុងការផ្តល់វគ្គបណ្តុះបណ្តាល ក៏ត្រូវបានធ្វើការកែប្រែ និងថែមទាំងបានផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិករបស់យើង ដើម្បីធានាថា ចំណេះដឹង និងការយល់ដឹងរបស់ពួកគេ បានឆ្លើយតបទៅនឹងការកាត់បន្ថយហានិភ័យនៃការមិនប្រតិបត្តិតាមហានិភ័យផ្នែកច្បាប់ និងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ នៅឆ្នាំ ២០២៤ យើងបានរៀបចំផែនការក្នុងការបង្កើតឲ្យមាននូវកម្មវិធីរៀបចំប្រព័ន្ធប្រតិបត្តិតាម ដែលរួមមាន ការធ្វើបច្ចុប្បន្នភាពលើរាល់គោលនយោបាយ បទបញ្ញត្តិ និងនីតិវិធី ដែលពាក់ព័ន្ធ បង្កើតឲ្យមាននូវបញ្ជីតាមដានការប្រតិបត្តិតាម និងកំណត់ពីផែនការក្នុងការតាមដាន និងត្រួតពិនិត្យ បង្កើតអោយមានកម្មវិធីសមស្របក្នុងការផ្តល់វគ្គបណ្តុះបណ្តាល និងយន្តការនៃការរាយការណ៍ ដើម្បីពង្រឹងមុខងារប្រតិបត្តិតាម ក្នុងការជួយឲ្យក្រុមហ៊ុនគ្រប់គ្រងការត្រួតពិនិត្យផ្ទៃក្នុងឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។



## ការគ្រប់គ្រងហានិភ័យ

ក្រុមហ៊ុនចាត់ទុកការគ្រប់គ្រងហានិភ័យ ជាធាតុសំខាន់មួយនៃអាជីវកម្ម និងបង្កប់វប្បធម៌ហានិភ័យរឹងមាំ នៅក្នុងប្រតិបត្តិការអាជីវកម្មពីមួយថ្ងៃទៅមួយថ្ងៃ។ ដោយយល់ច្បាស់អំពីសារៈសំខាន់នៃការគ្រប់គ្រងហានិភ័យ ដើម្បីឲ្យមានការរីកចម្រើនប្រកបដោយចីរភាព ក្រុមការងារគ្រប់គ្រងហានិភ័យបានចូលរួមក្នុងដំណាក់កាលដំណើរការគ្រប់គ្រងហានិភ័យ ដើម្បីផ្តល់នូវគំនិត និងទស្សនៈដោយឯករាជ្យ ដូចជាកាត្រួតពិនិត្យ ការរៀបចំផែនការ និងការដឹកនាំការគ្រប់គ្រងហានិភ័យរបស់ខ្លួនផ្ទាល់។ ក្រុមហ៊ុនបានរៀបចំអោយមាននូវកិច្ចប្រជុំការគ្រប់គ្រងហានិភ័យថ្នាក់តំបន់ប្រចាំខែ ដែលមានសមាសភាពចូលរួម ពីប្រទេសជប៉ុន ថៃ ភូមា និងឡាវ ដែលសុទ្ធសឹងជាក្រុមហ៊ុនសម្ព័ន្ធ នៃអ៊ីអនគ្រុប។

# សកម្មភាពចូលរួម ទំនួលខុសត្រូវសង្គម






## ចំណុចឆ្នើមបញ្ចាំងសម្រាប់ឆ្នាំ ២០២៣

នៅឆ្នាំ ២០២៣ យើងបានបន្តធ្វើការឧបត្ថម្ភដល់កម្មវិធីអប់រំ និងវប្បធម៌មួយរួមមានដូចជាកម្មវិធីប្រលងនិយាយភាសាជប៉ុន កម្មវិធីជជែកពិភាក្សា អ្នកបន្តវេន និងពិធីបុណ្យគីហ្សូណា។ ជាមួយគ្នានេះដែរ ពួកយើងក៏បានចូលរួមក្នុងសកម្មភាពរបស់អ៊ីអនគ្រុបដូចជា ពិធីផ្តល់អាហារូបករណ៍ក្លឹបអ៊ីអន ១% និង AEON Camp - សកម្មភាពជីកអណ្តូងនៅខេត្តតាកែវ។

| ខែ | ចំណាងជើង |
|---|---|
| កុម្ភៈ | ពិធីបុណ្យគីហ្សូណា រៀបចំដោយ CJCC |
| ឧសភា | ការបរិច្ចាគទៅកាន់កាកបាទក្រហមកម្ពុជា (ខួបអនុស្សាវរីយ៍៦០ឆ្នាំ) |
| មិថុនា | កម្មវិធីប្រលងនិយាយភាសាជប៉ុនលើកទី២៥ |
| មិថុនា | ការឧបត្ថម្ភទៅកាន់កម្មវិធីជជែកដេញដោល អ្នកបន្តវេន២០២៣ |
| កក្កដា | AEON Camp - សកម្មភាពជីកអណ្តូង |
| ធ្នូ | ផ្តល់អាហារូបករណ៍ក្លឹបអ៊ីអន ១% ដល់ "សាកលវិទ្យាល័យជាតិគ្រប់គ្រង និង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ" |

## ផែនការសំខាន់សម្រាប់ឆ្នាំ ២០២៤

សកម្មភាពសម្អាតទីក្រុងនឹងបន្តឡើងវិញ បន្ទាប់ពីមិនមានសកម្មភាពជាច្រើនឆ្នាំ។ យើងមានគម្រោងក្នុងការបន្តបរិច្ចាគដល់កាកបាទក្រហមកម្ពុជា លើបុព្វហេតុមនុស្សធម៌ ទន្ទឹមនឹងការរួមចំណែកគាំទ្រដល់គំនិតផ្តួចផ្តើមអប់រំផ្នែកហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជាផងដែរ។ សកម្មភាពទំនួលខុសត្រូវផ្នែកសង្គមជាមួយដៃគូខាងក្រៅដូចជាការបរិច្ចាគឈាម និងសកម្មភាពដាំដើមឈើគឺស្ថិតនៅក្នុងគម្រោងរបស់យើង។ លើសពីនេះ យើងទន្ទឹងរង់ចាំការគាំទ្រ និងចូលរួមក្នុងសកម្មភាពរបស់ អ៊ីអន គ្រុប។

| ចំណាងជើង |
|---|
| សកម្មភាពសម្អាតទីក្រុង នៅរាជធានីភ្នំពេញ |
| ការឧបត្ថម្ភទៅកាន់កម្មវិធីចំណេះដឹងហិរញ្ញវត្ថុ ផ្តួចផ្តើមដោយធនាគារជាតិនៃកម្ពុជា |
| ការបរិច្ចាគសម្ភារៈសិក្សា នៅខេត្តត្បូងឃ្មុំ |
| ការបរិច្ចាគទៅកាន់កាកបាទក្រហមកម្ពុជា |
| សកម្មភាពបរិច្ចាគឈាម រៀបចំដោយ SPBM |
| កម្មវិធីប្រលងនិយាយភាសាជប៉ុនលើកទី២៥ |
| ពិធីបុណ្យតាណាបាតា រៀបចំដោយ CJCC |
| សកម្មភាពដាំដើមឈើ |
| AEON Camp - សកម្មភាពជីកអណ្តូង |
| ផ្តល់អាហារូបករណ៍ក្លឹបអ៊ីអន ១% ដល់ "សាកលវិទ្យាល័យជាតិគ្រប់គ្រង និង សាកលវិទ្យាល័យភូមិន្ទភ្នំពេញ" |



# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

*នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣*

តួលេខចាប់ពីទំព័រ ១៧ ទៅ ២១ ត្រូវបានដកស្រង់ចេញពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤។

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ១.២៦១.១៥៩ | ៥.១៥១.៨៣៥ | ៨២៧.៩៧៨ | ៣.៤០៨.៧៨៥ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ១.៩៨៩.១២១ | ៨.១២៥.៥៥៩ | ៦.២០១.១៧៨ | ២៥.៥៣០.២៥០ |
| សមតុល្យនៅធនាគារផ្សេងៗ | ២.៤០៣.៣២៧ | ៩.៨១៧.៥៩១ | ៥.៩៨១.៣១៣ | ២៤.៦២៥.០៦៦ |
| ឥណទានផ្តល់ដល់អតិថិជន | ១៥១.៥៣០.៥២៦ | ៦១៩.០០២.១៩៩ | ១២០.៤៩០.១២៣ | ៤៩៦.០៥៧.៨៥៣ |
| ទ្រព្យសកម្មផ្សេងៗ | ៣.៤៩០.៦៩៧ | ១៤.២៥៩.៤៩៧ | ៣.២២៤.៤៦៨ | ១៣.២៧៥.១៣៥ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៣.០៤៤.០៧១ | ១២.៤៣៥.០៣០ | ១.៣៨៩.៨៨០ | ៥.៧២២.១៣៦ |
| ទ្រព្យសកម្មអរូបី | ២.២៥៥.០២៥ | ៩.២១១.៧៧៧ | ១.៩៨៤.២២៦ | ៨.១៦៩.០៥៨ |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | ១.២៧២.៩៧៩ | ៥.២០០.១១៩ | ១.៩៧៩.៤៧២ | ៨.១៤៩.៤៨៦ |
| ទ្រព្យសកម្មពន្ធពន្យារ | ១.៣៩២.៤៣៧ | ៥.៦៨៨.១០៥ | ១.៨៤០.១៩៤ | ៧.៥៧៦.០៧៩ |
| **ទ្រព្យសកម្មសរុប** | ១៦៨.៦៣៩.៣៤២ | ៦៨៨.៨៩១.៧១២ | ១៤៣.៩១៨.៨៣៦ | ៥៩២.៥១៣.៨៤៨ |
| **បំណុល** | | | | |
| បំណុលពន្ធចរន្ត | ៤២០.០១២ | ១.៧១៥.៧៤៩ | ៥១១.៦៤០ | ២.១០៦.៤២២ |
| បំណុលផ្សេងៗ | ៣.៣៣៣.១១០ | ១៣.៦១៥.៧៥៤ | ៣.៥២៨.៨៦៧ | ១៤.៥២៨.៣៤៥ |
| សំវិធានធនសម្រាប់ខ្ទង់ក្រៅតារាងតុល្យការ | ២៥០.៧៦៥ | ១.០២៤.៣៧៥ | ៣៥៦.៣៥០ | ១.៤៦៧.០៩៣ |
| ប្រាក់កម្ចី | ១១៩.៥៤២.៥០៥ | ៤៨៨.៣៣១.១៣៣ | ៩៦.៣៤៨.២២៣ | ៣៩៦.៦៦៥.៦៣៤ |
| អនុបំណុល | ៥.៦៩៩.៩០៣ | ២៣.២៨៤.១០៤ | ៧.៣២៦.៧០៧ | ៣០.១៦៤.០៥៣ |
| បំណុលភតិសន្យា | ១.២៦៣.២៨៥ | ៥.១៦០.៥១៩ | ១.៩០៤.១៩៥ | ៧.៨៣៩.៥៧១ |
| កាតព្វកិច្ចលើអត្ថប្រយោជន៍បុគ្គលិក | ៨៨.៤៥៦ | ៣៦១.៣៤៣ | ១០២.៥១៩ | ៤២២.០៧១ |
| **បំណុលសរុប** | ១៣០.៥៩៨.០៣៦ | ៥៣៣.៤៩២.៩៧៧ | ១១០.០៧៨.៥០១ | ៤៥៣.១៩៣.១៨៩ |
| **មូលធន** | | | | |
| ដើមទុន | ២០.០០០.០០០ | ៨១.៧០០.០០០ | ២០.០០០.០០០ | ៨២.៣៤០.០០០ |
| ប្រាក់ចំណេញរក្សាទុក | ១៨.០៤១.៣០៦ | ៧៣.៦៥៥.៥៧៤ | ១៣.៨៤០.៣៣៥ | ៥៦.៣៨៩.៥៨៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៤៣.១៦១ | - | ៥៩១.០៧៦ |
| **មូលធនសរុប** | ៣៨.០៤១.៣០៦ | ១៥៥.៣៩៨.៧៣៥ | ៣៣.៨៤០.៣៣៥ | ១៣៩.៣២០.៦៥៩ |
| **បំណុល និងមូលធនសរុប** | ១៦៨.៦៣៩.៣៤២ | ៦៨៨.៨៩១.៧១២ | ១៤៣.៩១៨.៨៣៦ | ៥៩២.៥១៣.៨៤៨ |

# របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣*

| | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ៣០.២១៥.៩០៥ | ១២៤.១៨៧.៣៧០ | ២៩.៩១៩.៣៧៩ | ១២២.២៨០.៥០២ |
| ចំណាយការប្រាក់ | (៥.៥៣៧.៧២៥) | (២២.៧៦០.០៥០) | (៤.០១៦.០៩៤) | (១៦.៤១៣.៧៧៦) |
| **ចំណូលសុទ្ធពីការប្រាក់** | ២៤.៦៧៨.១៨០ | ១០១.៤២៧.៣២០ | ២៥.៩០៣.២៨៥ | ១០៥.៨៦៦.៧២៦ |
| ចំណូលពីថ្លៃឈ្នួលនិងកម្រៃជើងសារ | ២.២៩៩.៩៧៥ | ៩.៤៥២.៨៩៧ | ២.២១០.៦២៩ | ៩.០៣៤.៨៤១ |
| ចំណូលផ្សេងៗសុទ្ធ | ១.៨៧៦.៦២៣ | ៧.៧១២.៩២១ | ១.៦១៦.៤៣៥ | ៦.៦០៦.៣៧០ |
| **ចំណេញពីប្រតិបត្តិការ** | ២៨.៨៥៤.៧៧៨ | ១១៨.៥៩៣.១៣៨ | ២៩.៧៣០.៣៤៩ | ១២១.៥០៧.៩៣៧ |
| ចំណាយបុគ្គលិក | (៩.៦៨១.០៨៤) | (៣៩.៧៨៩.២៥៥) | (៨.៦២៨.៨០៥) | (៣៥.២៦៥.៩២៦) |
| ចំណាយរំលស់ | (២.១៩៥.៦៥០) | (៩.០២៤.១២២) | (២.២០៥.៦៧៥) | (៩.០១៤.៥៩៤) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៧.៤៤៩.៥០១) | (៣០.៦១៧.៤៤៩) | (៦.៣៧៤.៤១៦) | (២៦.០៥២.២៣៨) |
| ការខាតបង់លើឱនភាពតម្លៃ | (៤.១៣៦.៧៣៨) | (១៧.០០១.៩៩៣) | (៣.៣៨២.៧៥៣) | (១៣.៨២៥.៣១២) |
| **ប្រាក់ចំណេញមុនដកពន្ធ** | ៥.៣៩១.៨០៥ | ២២.១៦០.៣១៩ | ៩.១៣៨.៧០០ | ៣៧.៣៤៩.៨៦៧ |
| ចំណាយពន្ធលើប្រាក់ចំណូល | (១.១៩០.៨៣៤) | (៤.៨៩៤.៣២៨) | (១.៨៦៤.៤៨៣) | (៧.៦២០.១៤២) |
| ប្រាក់ចំណេញក្នុងឆ្នាំ | ៤.២០០.៩៧១ | ១៧.២៦៥.៩៩១ | ៧.២៧៤.២១៧ | ២៩.៧២៩.៧២៥ |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៥៤៧.៩១៥) | - | ៥០០.៥៦៩ |
| **ចំណូលលម្អិតសរុបប្រចាំឆ្នាំ** | ៤.២០០.៩៧១ | ១៦.៧១៨.០៧៦ | ៧.២៧៤.២១៧ | ៣០.២៣០.២៩៤ |

# របាយការណ៍បម្រែបម្រួលមូលធន

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣*

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | សរុប | |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ២០.០០០.០០០ | ៨១.៤៨០.០០០ | ៦.៥៦៦.១១៨ | ២៦.៦៥៩.៨៥៨ | ៩០.៥០៧ | ២៦.៥៦៦.១១៨ | ១០៨.២៣០.៣៦៥ |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | ៧.២៧៤.២១៧ | ២៩.៧២៩.៧២៥ | - | ៧.២៧៤.២១៧ | ២៩.៧២៩.៧២៥ |
| លទ្ធផលលម្អិតផ្សេងៗ<br>- លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | ៥០០.៥៦៩ | - | ៥០០.៥៦៩ |
| **ចំណូលលម្អិតសរុបប្រចាំឆ្នាំ** | - | - | ៧.២៧៤.២១៧ | ២៩.៧២៩.៧២៥ | ៥០០.៥៦៩ | ៧.២៧៤.២១៧ | ៣០.២៣០.២៩៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៨៦០.០០០ | - | - | - | - | ៨៦០.០០០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | ២០.០០០.០០០ | ៨២.៣៤០.០០០ | ១៣.៨៤០.៣៣៥ | ៥៦.៣៨៩.៥៨៣ | ៥៩១.០៧៦ | ៣៣.៨៤០.៣៣៥ | ១៣៩.៣២០.៦៥៩ |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ២០.០០០.០០០ | ៨២.៣៤០.០០០ | ១៣.៨៤០.៣៣៥ | ៥៦.៣៨៩.៥៨៣ | ៥៩១.០៧៦ | ៣៣.៨៤០.៣៣៥ | ១៣៩.៣២០.៦៥៩ |
| ប្រាក់ចំណេញក្នុងឆ្នាំ | - | - | ៤.២០០.៩៧១ | ១៧.២៦៥.៩៩១ | - | ៤.២០០.៩៧១ | ១៧.២៦៥.៩៩១ |
| លទ្ធផលលម្អិតផ្សេងៗ<br>- លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | (៥៤៧.៩១៥) | - | (៥៤៧.៩១៥) |
| **ចំណូលលម្អិតសរុបប្រចាំឆ្នាំ** | - | - | ៤.២០០.៩៧១ | ១៧.២៦៥.៩៩១ | (៥៤៧.៩១៥) | ៤.២០០.៩៧១ | ១៦.៧១៨.០៧៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៦៤០.០០០) | - | - | - | - | (៦៤០.០០០) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | ២០.០០០.០០០ | ៨១.៧០០.០០០ | ១៨.០៤១.៣០៦ | ៧៣.៦៥៥.៥៧៤ | ៤៣.១៦១ | ៣៨.០៤១.៣០៦ | ១៥៥.៣៩៨.៧៣៥ |

# របាយការណ៍លំហូរសាច់ប្រាក់

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣*

| | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញមុនដកពន្ធ | ៥.៣៩១.៨០៥ | ២២.១៦០.៣១៩ | ៩.១៣៨.៧០០ | ៣៧.៣៤៩.៨៦៧ |
| និយ័តកម្មលើ៖ | | | | |
| កាតព្វកិច្ចលើអត្ថប្រយោជន៍បុគ្គលិក | (១៤.០៦៣) | (៥៧.៧៩៩) | (៣៣.៩៧៦) | (១៣៨.៨៦០) |
| ចំណាយរំលស់ | ២.១៩៥.៦៥០ | ៩.០២៤.១២២ | ២.២០៥.៦៧៥ | ៩.០១៤.៥៩៤ |
| ការខាតបង់លើឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ | ៤.១៣៦.៧៣៨ | ១៧.០០១.៩៩៣ | ៣.៣៨២.៧៥៣ | ១៣.៨២៥.៣១២ |
| (ចំណេញ)/ការខាតបង់ពីការលក់ និងលុបចោលទ្រព្យសម្បត្តិ និងបរិក្ខារ | (២.០៥០) | (៨.៤២៦) | ៣៥០ | ១.៤៣០ |
| ការខាតបង់ពីការលុបចោលទ្រព្យអរូបី | - | - | ១.៥៦១ | ៨៨.១២០ |
| ចំណូលការប្រាក់ | (៣០.២១៥.៩០៥) | (១២៤.១៨៧.៣៧០) | (២៩.៩១៩.៣៧៩) | (១២២.២៨០.៥០២) |
| ចំណាយការប្រាក់ | ៥.៥៣៧.៧២៥ | ២២.៧៦០.០៥០ | ៤.០១៦.០៩៤ | ១៦.៤១៣.៧៧៦ |
| ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ | ១៣១.៤៥២ | ៥៤០.២៦៨ | (២៦២.៥៨៣) | (១.០៨១.០៥៤) |
| | (១២.៨៣៨.៦៤៨) | (៥២.៧៦៦.៨៤៣) | (១១.៤៥០.៨០៥) | (៤៦.៨០៧.៣១៧) |
| *បម្រែបម្រួល៖* | | | | |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៥.១៩៤.៧៧៥ | ២១.៣៥០.៥២៥ | (៥៥២.១០៧) | (២.២៥៦.៤៦១) |
| ឥណទានផ្តល់ដល់អតិថិជន | (៣៥.២២៧.៩៩២) | (១៤៤.៧៨៧.០៤៧) | ២.៣៦២.០៣១ | ៩.៦៥៣.៦២១ |
| ទ្រព្យសកម្មផ្សេងៗ | (២៦៦.២២៩) | (១.០៩៤.២០១) | (៦៨៤.៥៧១) | (២.៧៩៧.៨៤២) |
| បំណុលផ្សេងៗ | (២២២.៥៦១) | (៩១៤.៧២៦) | ៦២០.៣២៩ | ២.៥៣៥.២៨៥ |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | (៤៣.៣៦០.៦៥៥) | (១៧៨.២១២.២៩២) | (៩.៧០៥.១២៣) | (៣៩.៦៧២.៧១៤) |
| ការប្រាក់បានទទួល | ៣០.១២៧.៦៩៨ | ១២៣.៨២៤.៨៣៩ | ៣០.៤៩២.៧០៨ | ១២៤.៦២៣.៦៩៨ |
| ការប្រាក់បានបង់ | (៥.៤១០.៧៥៨) | (២២.២៣៨.២១៥) | (៣.៨៥៧.៦១៩) | (១៥.៧៦៦.០៨៩) |
| ពន្ធលើប្រាក់ចំណូលបានបង់ | (៨៣៤.៧០៥) | (៣.៤៣០.៦៣៨) | (៦១៦.១៣៥) | (២.៥១៨.១៤៤) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/បានពីសកម្មភាពប្រតិបត្តិការ** | (១៩.៤៧៨.៤២០) | (៨០.០៥៦.៣០៦) | ១៦.៣១៣.៨៣១ | ៦៦.៦៦៦.៧៥១ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | (២.៣៨៦.០២៤) | (៩.៨០៦.៥៥៩) | (៨១០.០៨៤) | (៣.៣១០.៨១៣) |
| ការទិញទ្រព្យសកម្មអរូបី | (៧៣៨.២៨៥) | (៣.០៣៤.៣៥១) | (៥២៧.៦៥៥) | (២.១៥៦.៥២៦) |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៣.៨៣៧ | ១៥.៧៧០ | ១.០៣១ | ៤.២១៤ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | (៣.១២០.៤៧២) | (១២.៨២៥.១៤០) | (១.៣៣៦.៧០៨) | (៥.៤៦៣.១២៥) |

# របាយការណ៍លំហូរសាច់ប្រាក់ (ត)

*សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣*

| | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ៦៩.៣១១.០១៦ | ២៨៤.៨៦៨.២៧៦ | ២៤.៩០១.៦០៣ | ១០១.៧៧២.៨៥១ |
| ការទូទាត់សងប្រាក់កម្ចី | (៤៦.៣៧៥.១៥៣) | (១៩០.៦០១.៨៧៩) | (៣៦.១១៥.៨១២) | (១៤៧.៦០៥.៣២៤) |
| ការទូទាត់សងអនុបំណុល | (១.៦០០.០០០) | (៦.៥៧៦.០០០) | (៨០០.០០០) | (៣.២៦៩.៦០០) |
| ការទូទាត់សងប្រាក់ដើមភតិសន្យា | (៩៣២.៥៣៥) | (៣.៨៣២.៧១៩) | (១.០៤៨.២៧៥) | (៤.២៨៤.៣០០) |
| **សាច់ប្រាក់សុទ្ធបានពី/(ប្រើប្រាស់ក្នុង) សកម្មភាពហិរញ្ញប្បទាន** | ២០.៤០៣.៣២៨ | ៨៣.៨៥៧.៦៧៨ | (១៣.០៦២.៤៨៤) | (៥៣.៣៨៦.៣៧៣) |
| (ការថយចុះ)/ការកើនឡើង នូវសាច់ប្រាក់ និង សាច់ប្រាក់សមមូល | (២.១៩៥.៥៦៤) | (៩.០២៣.៧៦៨) | ១.៩១៤.៦៣៩ | ៧.៨១៧.២៥៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមឆ្នាំ | ៦.៨៧៤.៨៩៤ | ២៨.៣០៣.៩៣៨ | ៤.៩៦០.២៥៥ | ២០.២០៨.០៨០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១៦៥.១០៧) | - | ២៧៨.៦០៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងឆ្នាំ** | ៤.៦៧៩.៣៣០ | ១៩.១១៥.០៦៣ | ៦.៨៧៤.៨៩៤ | ២៨.៣០៣.៩៣៨ |

# គោលការណ៍មូលដ្ឋានរបស់អ៊ីអន

**ភាពមិនអាចខ្វះបានក្នុងការផ្សារភ្ជាប់អតិថិជន ជាមួយនឹងការស្វែងរកសន្តិភាព ការគោរព និងការចូលរួមដល់សហគមន៍ គឺជាមូលដ្ឋានគ្រឹះរបស់យើង។**

**អ៊ីអនជឿជាក់ថា អាជីវកម្មលក់រាយគឺជាឧស្សាហកម្មមួយ ដែលចូលរួមក្នុងការពង្រឹងសន្តិភាព មនុស្សធម៌ ហើយសហគមន៍មូលដ្ឋាន។ ដើម្បីបន្តរក្សាជាក្រុមសាជីវកម្មដ៏រីកចម្រើនមួយក្នុងការបំពេញបេសកម្មមួយនេះប្រកបដោយនិរន្តរភាព យើងបានប្តេជ្ញាបន្តនវានុវត្តន៍មិនឈប់ឈរដោយយកតម្រូវការអតិថិជនជាមូលដ្ឋានគ្រឹះនៃគោលគំនិតចាប់ផ្តើម។**

សន្តិភាពមិនអាចកើតឡើងបានដោយគ្មានការចូលរួមយ៉ាងសកម្ម និងមនសិការនោះទេ ទោះជាយើងដឹងថា សន្តិភាពបានមកពីការបញ្ចប់សង្គ្រាម ឬគ្រោះមហន្តរាយ និងការលើកកម្ពស់ជីវភាពរស់នៅឱ្យបានសុខសប្បាយក៏ដោយ។ គោលគំនិតនេះកើតមានឡើងពីបទពិសោធន៍ជាក់ស្តែងរបស់លោក Takuya Okada ប្រធានកិត្តិយស និងជាទីប្រឹក្សាជាន់ខ្ពស់របស់ប្រធានក្រុមសាជីវកម្ម។ ក្រោយសង្គ្រាមលោកលើកទី២ ពេលឃើញអតិថិជនតម្រង់ជួរនៅមុខហាងនានា កាន់ខិត្តប័ណ្ណបណ្តើរ យំបណ្តើរ ដោយនិយាយថា "សង្គ្រាមពិតជាចប់ហើយ" គាត់ក៏បានយល់ដឹងថា អត្ថិភាពនៃឧស្សាហកម្មលក់រាយគឺជានិមិត្តរូបនៃសន្តិភាព។ ចាប់ពីពេលនោះមក គាត់បានសម្រេចថា សន្តិភាពជាតម្រូវការអត្ថិភាពចំពោះមុខសម្រាប់ឧស្សាហកម្មលក់រាយ និង ថាឧស្សាហកម្មលក់រាយត្រូវចូលរួមចំណែកយ៉ាងសំខាន់ក្នុងការរក្សាសន្តិភាព។

សន្តិភាពគឺមិនមែនត្រឹមតែជាស្ថានភាពគ្មានសង្គ្រាម និងអំពើហិង្សាប៉ុណ្ណោះទេ។ ហើយ សន្តិភាព ក៏មិនមែនត្រឹមតែជាសេចក្តីសុខផ្លូវចិត្តនោះទេ ប៉ុន្តែវាជាការពុះពារងើបពីសង្គ្រាម ឬពីគ្រោះមហន្តរាយនានាដែលកើតមានឡើង។ ទោះជាបានឈានចូលដល់សតវត្សទី២១ ក៏ដោយ យើងទាំងអស់គ្នានៅតែជាសាក្សីនៃសង្គ្រាម និងគ្រោះមហន្តរាយធម្មជាតិនានា ដូចជាគ្រោះរញ្ជួយផែនដី និងអាកាសធាតុមិនប្រក្រតី ជាដើម កើតឡើងជាញឹកញាប់។ ពេលនេះហើយ គឺជាពេលដែលត្រូវធ្វើការវាយតម្លៃជាថ្មីឡើងវិញនូវគុណតម្លៃនៃសន្តិភាព។ សន្តិភាពមិនមែនបានមកដោយចៃដន្យទេ។ សន្តិភាព កើតឡើងដោយធាតុផ្សំសំខាន់២ នោះគឺការចូលរួម និងមនសិការ។

អ៊ីអននឹងមិនធ្វើសកម្មភាពណាដែលប្រឆាំងនឹងសន្តិភាពជាដាច់ខាត។ ហើយ អ៊ីអនក៏មិនពាក់ព័ន្ធនឹងអំពើ ឬសកម្មភាពណាដែលប្រឆាំងនឹងសន្តិភាពជាដាច់ខាត។ អ៊ីអនមានគោលបំណងចូលរួមយ៉ាងសកម្មដើម្បីសន្តិភាព។

យើងមានអារម្មណ៍ថាមានសុភមង្គលក្នុងជីវភាពរស់នៅ នៅពេលដែលយើងមានការជឿជាក់និងការគោរពគ្នាទៅវិញទៅមក ដែលប្រការនេះនឹងនាំមកនូវការពង្រីកសមត្ថភាព និងផ្តត់គំនិត និងមានទំនាក់ទំនងល្អជាមួយអ្នកដទៃ។

ប្រធានកិត្តិយសលោក Okada បានហៅឧស្សាហកម្មលក់រាយថាជា"ឧស្សាហកម្មមនុស្សធម៌" ។ នេះមានន័យថា ការគោរព "មាគ៌ាមនុស្ស" ដែលរួមមានការគោរពគ្នារវាងបុគ្គលម្នាក់ៗ សេចក្តីថ្លៃថ្នូរ និងស្វ័យភាព។ នេះក៏មានន័យថា ការជឿជាក់ទៅលើសក្តានុពលរបស់មនុស្ស និងការពង្រឹងសមត្ថភាព ដើម្បីឱ្យមានការរីកចម្រើនថែមទៀត និងក្លាយជាធនធានសក្តានុពល តាមរយៈការងារ និងការសិក្សាស្វែងយល់។ ទោះជាបានលើកឡើងខាងលើ ក៏វាជាការពិបាកសម្រាប់យើងក្នុងការរីកលូតលាស់តែម្នាក់ឯង ព្រោះមនុស្សគ្រប់រូបត្រូវការមាន "ទំនាក់ទំនងរវាងគ្នានិងគ្នា" ហើយ ត្រូវរីកចម្រើនជាមួយគ្នា។ ទាំងអស់នេះ ជាការយល់ដឹងពី សុភមង្គល និងជាគំរូបទដ្ឋានសម្រាប់អ្នករាល់គ្នា។ សរុបសេចក្តីមក ការលក់រាយគឺជាឧស្សាហកម្មនៃសុភមង្គល និងជាគំរូបទដ្ឋានរបស់មនុស្ស។

តំបន់នីមួយៗក៏ត្រូវគោរពភាពសម្បូរបែប និងស្វ័យភាពនៃតំបន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការពិសេសនៃតំបន់ និងថែរក្សាជាប្រចាំ ទើបអាចសម្រេចបាននូវសហគមន៍មួយដែលសំបូរសប្បាយបាន។

ដោយឈរលើមូលដ្ឋានឧស្សាហកម្មជាតំបន់ ការលក់រាយ គឺជាតំណភ្ជាប់ការរីកចម្រើនរបស់សមាគមន៍មូលដ្ឋាន។ ដើម្បីរក្សាបាននូវភាពសម្បូរបែប និងសុខុមាលភាពនៃតំបន់ និងសហគមន៍មូលដ្ឋាននៅក្នុងពួកគេ វាមានសារៈសំខាន់ណាស់ក្នុងការថែរក្សាពួកគេឱ្យបានខ្ជាប់ខ្ជួន។ នេះគឺជាបេសកកម្មដ៏សំខាន់មួយនៃឧស្សាហកម្មលក់រាយ។ ដោយសារការកើនឡើងនៃចំនួនថ្នាក់តំបន់ និងសហគមន៍មូលដ្ឋាន បានក្លាយជារឿងសំខាន់នាពេលអនាគត អ៊ីអន នឹងចូលរួមចំណែកយ៉ាងសកម្ម តាមរយៈការអភិវឌ្ឍផលិតផលដែលជាតម្រូវការទៅតាមតំបន់នីមួយៗ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនក្នុងតំបន់។

ទិសដៅរបស់អ៊ីអន គឺការចូលរួមយ៉ាងសកម្ម ដើម្បីសន្តិភាព ជំរុញសុភមង្គល និងគំរូបទដ្ឋានរបស់មនុស្សម្នា និងរួមចំណែកក្នុងការធ្វើឱ្យសមាគមន៍មូលដ្ឋានរីកចម្រើន។ នេះគឺជាការ "យកអតិថិជន" ជាមូលដ្ឋានគ្រឹះ ពោលគឺ គិតអតិថិជនជាចំបង។

ការគិតអតិថិជនជាចំបង គឺមិនគិតខ្លួនឯងជាមុនទេ មានន័យថា មិនគិត និងធ្វើសកម្មភាពទៅតាមទំនោរចិត្តរបស់ខ្លួនទេ។ ផ្ទុយទៅវិញ គឺត្រូវតែគិតអតិថិជនជាគោលគំនិតនៃចំនុចចាប់ផ្តើម ហើយធ្វើសកម្មភាពដោយស្មោះត្រង់នេះហើយ គឺជាមូលដ្ឋានគ្រឹះរបស់អ៊ីអន។ យើងនឹងប្រើវាជាកញ្ចក់មួយសម្រាប់ឆ្លុះមើលឃើញខ្លួនឯង និងជាស្តង់ដារសម្រាប់រាល់ការសម្រេចចិត្ត និងការធ្វើសកម្មភាពដោយអ៊ីអន។ តាមធម្មតា យើងមានទំនោរទៅរកអ្វីដែលមានប្រយោជន៍ ឬងាយស្រួលសម្រាប់ក្រុមហ៊ុនរបស់យើង និងខ្លួនយើង ក៏ប៉ុន្តែយើងត្រូវបដិសេធយ៉ាងម៉ឺងម៉ាត់នូវទំនោរបែបនេះ ហើយពុះពារឱ្យបានឈ្នះទំនោរនេះទាល់តែបាន។

ដូច្នេះហើយ អ៊ីអនត្រូវតែជាក្រុមសាជីវកម្មដែលបន្តនវានុវត្តន៍ជាប្រចាំ។

ការធានាឱ្យបាននូវការរីកចម្រើន និងការសុខដមរម្យនារបស់ក្រុមហ៊ុនគឺមានសារៈសំខាន់បំផុត ប៉ុន្តែបើគ្មានការច្នៃប្រឌិតឥតឈប់ឈរទេ ស្ថានភាពរបស់ក្រុមហ៊ុននឹងធ្លាក់ចុះ ហើយទីបំផុតអាចត្រូវវិនាស។ ការរក្សាបាននូវស្ថានភាពបច្ចុប្បន្ន ឱ្យមានស្ថេរភាព ហើយងាយស្រួលទៅបាន ក្រុមហ៊ុនមិនត្រូវនៅស្ងៀមទេ ប៉ុន្តែយើងត្រូវផ្លាស់ប្តូរនិងអភិវឌ្ឍន៍ខ្លួនឯងជានិច្ចជាកាល។ ការយល់ដឹងពីស្ថានភាពជាមុននិងសម្លឹងឆ្ពោះទៅមុខជានិច្ច ចំពោះការផ្លាស់ប្តូររបស់អតិថិជន និងសង្គម វាជាការចាំបាច់ក្នុងការបន្តនវានុវត្តន៍របស់យើង។ អ៊ីអន ត្រូវខំប្រឹងប្រែងប្រមើលមើលការវិវត្ត និងការផ្លាស់ប្តូរនានា ដែលជាតម្រូវការសម្រាប់ជីវភាពរស់នៅរបស់អតិថិជន និងសង្គម។

អ៊ីអនបានប្រែក្លាយពីអាជីវកម្មលក្ខណៈគ្រួសារទៅជាក្រុមហ៊ុនសាជីវកម្ម ហើយបន្ទាប់មកជាក្រុមហ៊ុនឧស្សាហកម្ម។ ទាំងនេះ វាជាការបន្តរក្សាវប្បធម៌សាជីវកម្មជាថាមវន្ត។ ស្របពេលដែលសង្គមកំពុងតែមានការប្រែប្រួលកាន់តែលឿនបែបនេះ អ្វីដែលយើងខ្លាចបំផុតនោះគឺ ការបាត់បង់នូវគំនិតច្នៃប្រឌិតដែលជាតម្រូវការ និងស្មារតីសហគ្រិនភាព ហើយបណ្តាលឱ្យធ្លាក់ចូលទៅក្នុងភាពជាប់គាំងដូចបណ្តាក្រុមហ៊ុនធំៗដទៃទៀត។ ការរក្សាសស្ថានភាពបច្ចុប្បន្នឱ្យនៅដដែល ដោយគ្មានការប្រែប្រួល មិនអាចបន្តការរក្សាលំនឹងបានឡើយ។ អ៊ីអនមានតែខំប្រឹងប្រែងច្នៃប្រឌិតនាំមុខជាអតិបរមា និងទំនើបកម្ម ដើម្បីជៀសវាងការដើរថយក្រោយពីនវានុវត្តន៍ថ្មីៗណាមួយ។ វាគឺជាការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់យើងក្នុងការក្លាយជាអង្គភាពមួយដែលបន្តអភិវឌ្ឍខ្លួនជានិច្ច ដោយឈរលើស្មារតីជាស្ថានិកនិងឈានមុខគ្រប់ពេលវេលា។

អ៊ីអន នឹងធ្វើសកម្មភាព ដែលជឿជាក់យ៉ាងម៉ឺនមាត់ថា តាមរយៈការបញ្ជ្រាបចូលនូវផ្នត់គំនិត និងការអនុវត្តដូចខាងលើនេះ យើងអាចចូលរួមចំណែកក្នុងការថែរក្សា និងធ្វើឱ្យល្អប្រសើរឡើងនៃ សន្តិភាព មនុស្សជាតិ និងសមាគមន៍មូលដ្ឋានបាន។

# ចក្ខុវិស័យរបស់ក្រុមហ៊ុនរបស់អ៊ីអន



## ចក្ខុវិស័យរបស់ក្រុមហ៊ុន

បង្កើតរបៀបរស់នៅនាពេលអនាគតដែល
នាំមកនូវស្នាមញញឹមដល់មនុស្សគ្រប់គ្នា



### អនាគតដែលអ៊ីអនគ្រុប ចង់សម្រេចបាន

នៅពេលអតិថិជនអាចរស់នៅក្នុង "សង្គមដែលមានភាពស្រស់ត្រកាលជាងមុន និងទទួលបាន "សុភមង្គលតាមបែបផែនរៀងៗខ្លួន"។ វាហាក់ដូចជាពួកគេ "ទទួលបាននូវការបំពេញចិត្តនិងពោរពេញទៅដោយស្នាមញញឹម"



### អ្វីដែលអ៊ីអនគ្រុប ចង់ក្លាយទៅជា

គ្រុបដែលដឹកនាំឲ្យមានការសហបង្កើត ការរស់នៅដែលមានគុណភាពដល់បុគ្គលនីមួយៗ ក៏ដូចជាសង្គមទាំងមូល

### ឥរិយាបថនិងការប្តេជ្ញា ដែលយើងគោរពឲ្យតម្លៃ

~ឥរិយាបថទាំង៣~

"ប្រព្រឹត្តទៅតាមដំណើរធម្មជាតិនិងដើរតាមក្តីស្រមៃ"
បន្តការរៀនសូត្រដើម្បីបង្កើតគុណតម្លៃថ្មីបន្ថែមទៀត"
ថែរក្សាទំនាក់ទំនង និងរួមសហការគ្នា"

~ការប្តេជ្ញាទី១~

"តែងតែសម្តែងនូវភាពសុចរិត និងទៀងត្រង់"



# អំពីអុីអនគ្រុប

## ប្រវត្តិនៃការបង្កើត "វត្ថុបំណង”

### Our Purpose




ក្រុមហ៊ុន AEON Financial Services Group (AFS Group) បានចាប់ផ្តើមធ្វើអាជីវកម្មតាំងពីឆ្នាំ ១៩៨១ ជាក្រុមហ៊ុនផ្តល់ ប័ណ្ណឥណទាន និង សេវាកម្មហិរញ្ញវត្ថុផ្សេងៗ ដល់អតិថិជន ដែលទិញទំនិញនៅ ហាងលក់ទំនិញទូទៅ Jusco។ ការបើកសម្ពោធ សាខាហុងកុង នៅឆ្នាំ ១៩៨៧ បានបង្ហាញពីការចាប់ផ្តើម ប្រតិបត្តិការដំបូង នៅក្នុងបណ្តារប្រទេសអាសុី ផ្សេងៗទៀត។ យើងបានផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុ ដោយ សម្របទៅតាមលក្ខខណ្ឌក្នុងស្រុក រួមទាំង ការផ្តល់ជូននូវសេវាកម្មបង់រំលស់ សម្រាប់អតិថិជន ដែលមាន ការលំបាកក្នុងការទទួលបានសេវាកម្មហិរញ្ញវត្ថុ។ ធនាគារ AEON ដែលបានបង្កើតឡើងនៅប្រទេសជប៉ុនក្នុងឆ្នាំ ២០០៧ បានឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន និងបានស្តារឡើងវិញនូវវិស័យធនាគារតាមរយៈគំនិតផ្តួចផ្តើមថ្មីៗដូចជាការបើកដំណើរការ៣៦៥ថ្ងៃ និងការលុបបំបាត់សៀវភៅគណនី។ ឥឡូវនេះ AFS Group កំពុងនាំមកនូវភាពងាយស្រួល និងភាពរីកចម្រើន ដល់ជីវភាពអតិថិជនរបស់ខ្លួន នៅក្នុង ១១ប្រទេស ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ការផ្លាស់ប្តូរបរិបទអាជីវកម្ម បានបង្កើនល្បឿនកាន់តែឆាប់រហ័ស។ ការផ្លាស់ប្តូរនេះរួមមាន ការកើនឡើងនៃដៃគូប្រកួតប្រជែងក្នុងវិស័យហិរញ្ញវត្ថុ ដែលចេញមកពីវិស័យផ្សេងទៀត ការរីកចំរើនផ្នែកបច្ចេកវិទ្យាឌីជីថល និងការឲ្យតម្លៃផ្សេងៗគ្នារបស់អតិថិជន។ លើសពីនេះទៀត ក៏មានការកើនឡើង នូវវិបត្តិពិភពលោក រួមមាន បញ្ហាបម្រែបម្រួលអាកាសធាតុ និងបញ្ហាសិទ្ធិមនុស្ស ទន្ទឹមនឹងនេះសង្គមបច្ចុប្បន្ន ក៏កំពុងប្រឈមមុខនឹង ការកើនឡើងនៃភាពមិនប្រាកដប្រជា និងភាពស្មុគស្មាញផងដែរ។

ដើម្បីបន្តអាជីវកម្ម និងបន្តការរីកចម្រើននៅក្នុងសម័យកាលបែបនេះ ដំបូងយើងត្រូវតែក្លាយជាក្រុមហ៊ុនមួយ ដែលអាចប្រមូលធនធានប្រកបដោយទេពកោសល្យចម្រុះ និងអាចផ្តល់លទ្ធភាពឲ្យពួកគេដើរតួនាទីយ៉ាងសកម្ម។ ចុងក្រោយ ឆន្ទៈ និងគុណតម្លៃ គឺជាផ្នាក់ដ៏សំខាន់សម្រាប់ធនធានមនុស្សទាំងនេះ។ យោងតាមគោលការណ៍នេះ យើងត្រូវតែជំរុញឲ្យមានការផ្លាស់ប្តូរ ដោយជំរុញឲ្យបុគ្គលិក ធ្វើការត្រិះរិះពិចារណា និងអនុវត្តដោយឯករាជ្យប្រកបដោយស្វ័យភាព អំពីអ្វីដែលពួកគេអាចធ្វើបាន ដើម្បីធ្វើឲ្យជីវភាពរបស់អតិថិជន កាន់តែប្រសើរឡើង។

ដូច្នេះ យើងបានបង្កើត វត្ថុបំណងមួយ ដើម្បីកំណត់គោលដៅ របស់ AFS Group និងមូលដ្ឋានគ្រឹះក្នុងការប្រកបអាជីវកម្ម។

## ដើម្បីនាំ "មូលដ្ឋានហិរញ្ញវត្ថុ" ខិតទៅឲ្យកាន់តែជិតមនុស្សគ្រប់គ្នា

ក្នុងនាមជាស្ថាប័នផ្តល់សេវាកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន AEON Group យើងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដែលមានភាពងាយស្រួល និងងាយយល់ ដោយផ្អែកលើតម្រូវការរបស់អ្នកប្រើប្រាស់។ យើងក៏បានផ្តោតលើការលើកកម្ពស់ ការអប់រំចំណេះដឹងហិរញ្ញវត្ថុ សម្រាប់ប្រជាជនគ្រប់វ័យ និងនាំយន្តការហិរញ្ញវត្ថុឲ្យកាន់តែខិតទៅជិតមនុស្សគ្រប់គ្នា តាមរយៈការបញ្ចូលហិរញ្ញវត្ថុ ដែលឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុផ្សេងៗគ្នា។

## ដោយផ្សារភ្ជាប់ជាមួយមនុស្សម្នាក់។ដោយភាពស្មោះត្រង់

យើងធ្វើការទំនាក់ទំនងយ៉ាងយកចិត្តទុកដាក់ និងស្មោះត្រង់ ជាមួយអតិថិជនគ្រប់គ្នា ក្នុងការផ្តល់នូវសេវាកម្មហិរញ្ញវត្ថុ ដែលសម្របទៅនឹងការផ្លាស់ប្តូរ នៃដំណាក់កាលជីវិតនីមួយៗ និង បរិស្ថានរស់នៅ។ យើងក៏ បង្កើតនូវគុណតម្លៃថ្មី ដោយសហការជាមួយដៃគូពាណិជ្ជកម្មផ្សេងៗនៅក្នុងសហគមន៍រួមមាន ដៃគូសហការដែលបានចូលរួម និងអាជ្ញាធរមូលដ្ឋានផងដែរ។ ការធ្វើសកម្មភាព ដោយផ្អែកលើតម្រូវការរបស់អតិថិជន គឺជាគុណតម្លៃស្នូលមួយរបស់យើង។

## យើងនឹងធ្វើឲ្យការរស់នៅប្រចាំថ្ងៃកាន់តែមានភាពស្រស់បំព្រង ជាមួយនឹងភាពជឿជាក់ និងរីករាយ

ក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុ ដែលគាំទ្រជីវភាពរស់នៅប្រចាំថ្ងៃរបស់អតិថិជន យើងធ្វើឲ្យជីវភាពរបស់ពួកគេ មានភាពរីកចម្រើន និងជួយឲ្យពួកគេទទួលបាននូវសុភមង្គល។ យើងគោរពភាពខុសគ្នារបស់បុគ្គលិកម្នាក់ៗ និងឲ្យតម្លៃលើបរិយាកាសការងារ និងវប្បធម៌របស់ក្រុមហ៊ុនដែលអនុញ្ញាតឲ្យយើងធ្វើការប្រកបដោយមោទនភាព និងស្មារតីនៃសេរីភាព និងគំនិតបើកចំហ។ ដូច្នេះ យើងអាចផ្តល់គុណតម្លៃដល់ពួកគេដោយបំពេញការរស់នៅប្រចាំថ្ងៃជាមួយនឹងភាពជឿជាក់ និងស្នាមញញឹម ព្រមជាមួយអារម្មណ៍ស្រស់ស្រាយ និងភាពសប្បាយរីករាយ។

ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី

ÆON SPECIALIZED BANK (CAMBODIA) PLC.

អំពីយើង

ABOUT US